**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
ក្រសួងមហាផ្ទៃ

លេខ ០០១ ស.រ

ភ្នំពេញ ថ្ងៃទី ៣០ ខែ ១១ ឆ្នាំ២០០១

សារាចរ

**ស្តីពីផែនការបង្ការ បង្ក្រាប និងទប់ស្កាត់**
**ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់**
**នៅតាមខេត្ត ក្រុងនានា**

※※※※※

សភាពការណ៍បទល្មើសគ្រឿងញៀន កំពុងបន្តកើតមាន និងកាន់តែមានកំរិតកើនឡើងគួរឱ្យព្រួយបារម្ភ នៅតាមទីប្រជុំជនខេត្ត ក្រុង និងបណ្តាស្រុកមួយចំនួនជាប់តំបន់ព្រំដែន ។ សកម្មភាពជួញដូរ និងប្រើប្រាស់គ្រឿងញៀនជាមុខព្រួញដ៏សំខាន់មួយ ដែលរាជរដ្ឋាភិបាលកំពុងខិតខំយកចិត្តទុកដាក់ដោះស្រាយ ។

ដើម្បីធានាបង្ការ បង្ក្រាប និងទប់ស្កាត់ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ នៅតាមខេត្ត ក្រុងទូទាំងប្រទេស ក្រសួងមហាផ្ទៃដាក់ចេញសារាចរដើម្បីណែនាំអនុវត្តន៍ផែនការបង្ការបង្ក្រាប និងទប់ស្កាត់ដូចខាងក្រោម :

១-ពង្រឹងអនុវត្តន៍វិធានការជំនាញឱ្យបានខ្លាំងក្លា និងព្រមៗគ្នានៅទូទាំងប្រទេស ។ វិធានការជំនាញត្រូវអនុវត្តន៍ជាជំហានៗ ដោយត្រូវយកចិត្តទុកដាក់ :

-តម្លើងបញ្ជីមាតិការសមាសភាពជាមុខសញ្ញាក្នុងនោះរួមមាន ប្រភេទមេក្លោង សមាសភាពពាក់ព័ន្ធឧក្រិដ្ឋជនគ្រឿងញៀនឆ្លងដែន មុខសញ្ញាផលិតគ្រឿងញៀន មុខសញ្ញាចែកចាយ ម្ចាស់អាជីវកម្ម សេវាកម្មស្របច្បាប់ តែប្រើប្រាស់គ្រឿងញៀនដើម្បីទាក់ទាញភ្ញៀវ ប្រភេទក្មេង ញៀនការហិត អ្នកចាក់ដក់គ្រឿងញៀន (គិតទាំងជនបរទេសផង) ។

-បន្ទាប់ពីការតម្លើងបញ្ជីមុខសញ្ញាទាំងនោះរួចហើយ ត្រូវអនុវត្តន៍វិធានការគ្រប់គ្រងឱ្យបានម៉ត់ចត់ ប្រមែប្រមូលពត៌មានបង្ក្រង ប្រមូលវត្ថុតាង ដើម្បីឈានទៅបើកករណីតស៊ូបង្ក្រាបតាមនិតិវិធីច្បាប់ ។

២-ក្រោយការតម្លើងបញ្ជីមាតិការួចហើយ ត្រូវធ្វើការបែងចែកប្រភេទ និងអនុវត្តន៍វិធានការដូចខាងក្រោម :

ក-មុខសញ្ញាមេក្លោង សមាសភាពពាក់ព័ន្ធខ្សែក្រិដ្ឋជនគ្រឿងញៀនឆ្លងដែន មុខសញ្ញាផលិតគ្រឿងញៀន មុខសញ្ញាចែកចាយ ត្រូវជំរុញការប្រមែប្រមូលព័ត៌មាន វត្ថុតាង ដើម្បីឈានទៅបង្ក្រាបចាប់ផ្តន្ទាទោសតាមច្បាប់ ។

ខ-មុខសញ្ញាចាក់ជក់ ក្មេងញៀនការហិត ត្រូវប្រមូលផ្តុំ ដើម្បីធ្វើការអប់រំ ព្យាបាលតាមកំរិតលទ្ធភាពជាក់ស្តែងដែលយើងមាន ។ អាជ្ញាធរខេត្ត ក្រុង ត្រូវម្ចាស់ការទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជួយឧបត្ថម្ភក្នុងការបង្កើតមជ្ឈមណ្ឌលអប់រំ ព្យាបាល និងឈានទៅអប់រំនិតិសម្បទា ។

គ-គោលដៅអាជីវកម្មទាំងឡាយ ដែលសង្ស័យថាមានការចែកចាយ ឬប្រើប្រាស់គ្រឿងញៀន ដើម្បីទាក់ទាញភ្ញៀវ ត្រូវកោះអញ្ជើញធ្វើការអប់រំ និងចុះកិច្ចសន្យាមិនឱ្យមានការចែកចាយ ឬ ប្រើប្រាស់គ្រឿងញៀននៅទីនោះ ។ ទន្ទឹមនោះត្រូវធ្វើការតាមដានជាប់ជាប្រចាំនៅតាមគោលដៅអាជីវកម្មទាំងនោះ ។

៣-ធ្វើសេចក្តីជូនដំណឹងជូនអាជ្ញាធរដែនដី ដើម្បីជូនដំណឹងដល់គ្រប់គោលដៅអាជីវកម្មទាំងអស់ ជាពិសេសភោជនីយដ្ឋាន ក្លិបកំសាន្ត ក្លិបខារ៉ាអូខេ ម៉ាស្សា រង្គសាល សណ្ឋាគារ ដោយបិទបំរាមហាមឃាត់មិនឱ្យមានការចែកចាយ ឬ ប្រើប្រាស់គ្រឿងញៀន ដោយឱ្យម្ចាស់គោលដៅទាំងនោះចុះកិច្ចសន្យាជាមួយអាជ្ញាធរមានសមត្ថកិច្ច (ការជូនដំណឹងខាងលើត្រូវធ្វើជាប្រកាសរបស់សាលាខេត្ត ក្រុង) ។

-គោលដៅអាជីវកម្មណាដែលធ្វើល្មើសនឹងសេចក្តីប្រកាស ត្រូវអនុវត្តន៍ទណ្ឌកម្មតាមរូបភាពព្រមាន ឬ បិទការធ្វើអាជីវកម្មជាបណ្តោះអាសន្នដោយមានកំណត់រយៈពេល ឬ បិទការធ្វើអាជីវកម្មដោយគ្មានកំណត់ពេល ឬ បិទជាស្ថាពរ ឬ ត្រូវចោទប្តឹងទៅតុលាការវិនិច្ឆ័យទោសតាមច្បាប់ ។

៤-សហការជាមួយស្ថាប័នពាក់ព័ន្ធ មានវិធានការគ្រប់គ្រងឱ្យបានម៉ត់ចត់បំផុតក្រុមហ៊ុន ដែលសុំច្បាប់នាំចូលសារធាតុគីមី ដែលជាវត្ថុធាតុដើមអាចយកមកច្នៃផលិតគ្រឿងញៀនសំយោគបាន ។ ត្រូវធ្វើការប៉ាន់ប្រមាណធៀបផលិតផលសំរេចទៅនឹងសារធាតុគីមីដែលជាវត្ថុធាតុដើម ជៀសវាងការនាំចូលលើសសេចក្តីត្រូវការ នៃការផលិត ។

-ពេលដែលសារធាតុគីមីទាំងនោះធ្វើការនាំចូលមកហើយ ត្រូវបន្តធ្វើការគ្រប់គ្រងធ្វើយ៉ាងណាឱ្យសារធាតុគីមីទាំងនោះយកទៅប្រើប្រាស់ចំតាមគោលដៅ ។

៥-អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវសហការជាមួយអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាមួយប្រព័ន្ធឃោសនា និងជាមួយអង្គការមិនមែនរដ្ឋាភិបាល បង្កើនការអប់រំក្នុងជួរប្រជាពលរដ្ឋ សិស្សានុសិស្ស មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ឱ្យយល់ដឹងពីគ្រោះមហន្តរាយបណ្តាលមកពីគ្រឿងញៀន និងចូលរួមយ៉ាងសស្រាក់សស្រាំក្នុងការប្រយុទ្ធប្រឆាំងការជួញដូរ ការប្រើប្រាស់គ្រឿង

[illegible]

៦-ដើម្បីចាត់តាំងឱ្យមានប្រសិទ្ធភាពសារាចរខាងលើនោះ ក្រសួងមហាផ្ទៃកំណត់ឱ្យខេត្ត ក្រុងនិមួយៗ បង្កើតគណៈកម្មការចំរុះមួយ ដឹកនាំដោយឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល និងឯកឧត្តមអភិបាលខេត្ត ដើម្បីជំរុញដឹកនាំតាមស្មារតីសារាចរនេះ ។

ចំពោះមុខប្រគល់ជូនឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុករាជធានីភ្នំពេញ ចាត់តាំងដឹកនាំអនុវត្តន៍ស្មារតីសារាចរនេះមុនគេរយៈពេល ០៣ខែ ដើម្បីដកបទពិសោធន៍ បន្ទាប់មកនឹងធ្វើការចាត់តាំងផ្សព្វផ្សាយបទពិសោធន៍នេះ ជូនដល់ ខេត្ត ក្រុងទូទាំងប្រទេស ដើម្បីចាត់តាំងអនុវត្តន៍ឱ្យបានព្រមគ្នា ។

ទទួលបានសារាចរនេះ អគ្គនាយកនគរបាលជាតិ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ឯកឧត្តមអភិបាលខេត្ត ក្រុង ត្រូវធ្វើការផ្សព្វផ្សាយ ណែនាំ ជ្រាបដល់មន្ត្រីទទួលបន្ទុកអនុវត្តន៍ផ្ទាល់ ដើម្បីចាត់តាំងអនុវត្តន៍ឱ្យមានប្រសិទ្ធភាព ។

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង យូ ហុកគ្រី

<u>ចម្លងជូន</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
-ក្រសួងការពារជាតិ
-ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងសង្គមកិច្ច យុវនីតិសម្បទា
"ដើម្បីជូនជ្រាប"
-អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
-ទីបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
"ដើម្បីសហការអនុវត្តន៍"
-អគ្គនាយកដ្ឋាននគរបាលជាតិ
-គ្រប់សាលា ខេត្ត ក្រុង
-គ្រប់ស្នងការដ្ឋាននគរបាលខេត្ត ក្រុង
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ